## សុន្ទរកថាបើកសន្និបាតលើកទី ២៣
## របស់គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា
## ថ្លែងដោយសម្តេច ជា ស៊ីម ប្រធានគណបក្ស
## ( ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៧ )

********

សូមគោរពគណៈអធិបតី !

សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃអង្គសន្និបាត ជាទីស្នេហា !

ថ្ងៃនេះ យើងប្រារព្ធបើកសន្និបាត លើកទី ២៣ របស់គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ស្របពេលដែលសភាពការណ៍ប្រទេសជាតិកំពុងឈានចូលរបត់ថ្មី ដែលមានភាពអនុគ្រោះច្រើនជាងមុននៃដំណើរការពង្រឹងសន្តិភាព ស្ថិរភាព លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការកសាងនីតិរដ្ឋ ពិតមែននៅមានការលំបាកស្មុគស្មាញមួយចំនួនទៀតដែលត្រូវប្រឈមមុខដោះស្រាយ ។

គណបក្សប្រជាជនកម្ពុជារបស់យើងបាននិងកំពុងអនុវត្តយ៉ាងសកម្មនូវទិសដៅ និងកម្មវិធីនយោបាយ ដែលបានលើកឡើងដោយមហាសន្និបាតវិសាមញ្ញរបស់គណបក្សនាខែ មករា ឆ្នាំ ១៩៩៧ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះឧត្តមប្រយោជន៍ជាតិ និងប្រជាជន បន្តពង្រឹងនូវសាមគ្គីភាពឯកភាពផ្ទៃក្នុងរឹងមាំ ដែលជាប្រពៃណីដ៏ល្អប្រពៃថ្លៃថ្លារបស់គណបក្ស ទោះបីកំលាំងប្រឆាំងខិតខំរកគ្រប់វិធីដើម្បីបំផ្លិចបំផ្លាញយ៉ាងណាក្តី ។

ពិនិត្យឡើងវិញចំពោះព្រឹត្តិការណ៍ដែលកើតមានឡើងចុងក្រោយនេះ គណបក្សយើងតែងបានប្រកាន់ខ្ជាប់នូវជំហរអត់ធ្មត់ ខិតខំសំរបសំរួល និងធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីរក្សាស្ថិរភាពនយោបាយនិងសង្គមសំរាប់ការស្តារនិងអភិវឌ្ឍន៍ប្រទេស ។ ប៉ុន្តែ អាស្រ័យដោយមហិច្ឆតាល្មោភអំណាចរបស់ក្រុមរណឫទ្ធិ និងបក្សពួក គេបានបង្កើនសកម្មភាពអនាធិបតេយ្យល្មើសច្បាប់កាន់តែខ្លាំងឡើង រហូតដល់ឃុបឃិតជាមួយពួកឧទ្ទាមខ្មែរក្រហមក្រៅច្បាប់ រៀបចំផែនការដណ្តើមអំណាចដោយកំលាំងយោធា ។ នោះគឺជាអំពើល្មើសច្បាប់ដ៏ធ្ងន់ធ្ងរ គំរាមកំហែងដល់អាយុជីវិតប្រទេសជាតិ និងប្រជាជន ។ មកដល់ពេលនេះមានភស្តុតាង និងសាក្សី ជាច្រើនបានបង្ហាញច្បាស់នូវអំពើល្មើសច្បាប់ដ៏ធ្ងន់ធ្ងររបស់ក្រុមរណឫទ្ធិ និងបក្សពួក ដែលតុលាការនឹងវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។ គណបក្សប្រជាជនកម្ពុជា គាំទ្រពេញទំហឹងនូវវិធានការរបស់រាជរដ្ឋាភិបាល និងកងកំលាំងប្រដាប់អាវុធជាតិ នៅថ្ងៃទី ៥-៦ កក្កដា ដែលជាប្រការចាំបាច់ខានពុំបាន ដើម្បីពង្រឹងឡើងវិញនូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ រក្សាសេចក្តីសុខជូនប្រជាជន ហើយទទួលបានជោគជ័យក្នុងការទប់ស្កាត់បានទាន់ពេលវេលានូវឧបាយកលពិសពុលនៃសម្ព័ន្ធភាពឃុបឃិតជាមួយពួកប្រល័យពូជសាសន៍ ការពារបានផលប្រយោជន៍ជា

អាយុជីវិតរបស់ប្រទេសជាតិនិងប្រជាជន បញ្ចប់ភាពតានតឹងប្រឈមមុខគ្នាដោយកំលាំង បង្កលក្ខណសម្បត្តិអនុគ្រោះថ្មីសំរាប់ដំណើរឈានទៅមុខរបស់កម្ពុជា ។

គណបក្សប្រជាជនកម្ពុជានឹងបន្តរក្សាជំហររឹងមាំក្នុងការពង្រឹងស្ថិរភាពនយោបាយនិងសង្គម ការការពារនិងអនុវត្តនូវរដ្ឋធម្មនុញ្ញ ការបន្តនិរន្តរភាពនៃគ្រប់ស្ថាប័នរដ្ឋ ដោយរក្សាសមិទ្ធផលនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងការបោះឆ្នោតឆ្នាំ ១៩៩៣ ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ។ គាំទ្រគោលការណ៍រៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៨ ក្រោមការចាត់ចែងរបស់កម្ពុជាផ្ទាល់ ដោយមានការចូលរួមសង្កេតការណ៍របស់អន្តរជាតិ និងគាំទ្រនូវរាល់វិធានការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំបរិយាកាសនយោបាយអព្យាក្រឹត និងសន្តិសុខសាធារណៈសំរាប់ការបោះឆ្នោតនាពេលខាងមុខ ។

គណបក្សប្រជាជនកម្ពុជាអបអរសាទរចំពោះប្រទេសជាមិត្តជិតឆ្ងាយ ដែលបានបន្តផ្តល់ជំនួយនិងការគាំទ្រដល់បុព្វហេតុជាតិ និងប្រជាជនកម្ពុជា ។ សូមស្វាគមន៍ចំពោះបំណងរបស់សហគមន៍អន្តរជាតិក្នុងការរួមចំណែកដល់សន្តិភាព និងស្ថិរភាពនៅកម្ពុជា ដោយឈរលើគោលការណ៍គោរពអធិបតេយ្យជាតិ និងសិទ្ធិស្វ័យសំរេចរបស់កម្ពុជា ។ សូមអោយអង្គការសហប្រជាជាតិប្រគល់អាសនៈកម្ពុជាជូនដល់តំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងគ្រប់គ្រងដឹកនាំប្រទេស ជាតំណាងស្របច្បាប់របស់ប្រជាជនកម្ពុជា ។ /

សន្និបាតគណៈកម្មាធិការកណ្តាលលើកនេះ នឹងគូសបញ្ជាក់នូវជំហានថ្មីរបស់គណបក្សយើង ក្នុងការបន្តអនុវត្តន៍កម្មវិធីនយោបាយរបស់គណបក្ស ដើម្បីបុព្វហេតុសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យសេរី និងការស្តារអភិវឌ្ឍន៍ប្រទេសជាតិ ។

ក្នុងឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ មន្ត្រីសមាជិក សមាជិកាគណបក្សគ្រប់រូប ដែលបានចូលរួមយ៉ាងសកម្ម អនុវត្តរាល់ភារកិច្ចនយោបាយរបស់គណបក្សប្រកបដោយការលះបង់ ពុះពារជំនះរាល់ការលំបាកស្មុគស្មាញ ដើម្បីបុព្វហេតុដ៏ត្រឹមត្រូវរបស់គណបក្ស ហើយទទួលបានលទ្ធផលល្អប្រសើរ ។

ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ សន្និបាតលើកទី ២៣ របស់គណៈកម្មាធិការកណ្តាល មានភារកិច្ចដូចតទៅ ÷

១ - ឆ្លង និងអនុម័តរបាយការណ៍ ស្តីពីសភាពការណ៍ និងការងាររបស់គណបក្ស តាំងពីក្រោយមហាសន្និបាតវិសាមញ្ញដល់បច្ចុប្បន្ន និងទិសដៅភារកិច្ចសំរាប់រយៈពេលបន្ត ។

២ - ឆ្លងនិងអនុម័តសេចក្តីសំរេចចិត្ត ស្តីពីផែនការឆ្ពោះទៅកាន់ការបោះឆ្នោត ឆ្នាំ ១៩៩៨ ។

៣ – ឆ្លងនិងអនុម័តបទបញ្ជាផ្ទៃក្នុងគណបក្ស ។

សន្និបាតនឹងដំណើរការរយៈពេល ២ ថ្ងៃកន្លះ តាមរបៀបវារៈដែលបានកំណត់ ។

សមាជិកគណៈកម្មាធិការកណ្តាលចូលរួមសន្និបាតមានវត្តមានចំនួន 141 រូប អវត្តមានចំនួន 142 រូប។ ក្រៅពីនេះ គណៈអចិន្ត្រៃយ៍ បានអញ្ជើញមន្ត្រីគណបក្សជាសមាជិកសភា តំណាងគណៈកម្មាធិការគណបក្ស ខេត្ត ក្រុង ក្រសួង ស្ថាប័ន និងទីប្រឹក្សាចំនួន....... រូប ចូលរួមសន្និបាតនេះដែរ ។

ខ្ញុំសូមប្រកាសបើកសន្និបាត និងសូមប្រសិទ្ធិពរអោយអង្គសន្និបាតសំរេចបានជោគជ័យ ។

សូម អរ គុណ !